# ការសំភាសន៍របស់អ៊ុំស្រី ហែម សុថេន

**កៈ អ្នកសំភាសន៍៖ កុសល្យវឌ្ឍនះ និមល ខៈ អ្នកត្រូវគេសំភាសន៍៖ ហែម សុថេន**

កៈ អញ្ចឹងអើ ជាដំបូងខ្ញុំសូមអរគុណអ៊ុំ ដែរបានអនុញ្ញាតិអោយខ្ញុំមកសំភាសន៍អ៊ុំថ្ងៃនេះ ហើយអ៊ុំនាក់សំភាសន៍ខ្ញុំឈ្មោះ កុសល្យ វឌ្ឍនះ និមល ថ្ងៃខែសំភាសន៍គឺនៅថ្ងៃទី ០២ ខែ ១២ ឆ្នាំ ២០១៧។ ហើយទីតាំងសំភាសន៍គឺនៅភូមិស្វាយចេកថ្មី អើ ឃុំព្រែកផ្ទៅ សង្កាត់សែកសុក ក្រុងភ្នំពេញ។ ហើយអញ្ចឹងអ៊ុំអើ ការសំភាសន៍ទាំងអស់នេះគឺត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅសហរដ្ឋអាមេរិកហាអ៊ុំ ដែរមានឈ្មោះថា BYU ហើយគោលបំណងរបស់សាលារគឺចង់ជួយដល់ប្រជាជនខ្មែរនឹងសមាជិកខ្មែរទាំងអស់គាត់អាចមានឱកាសថែរក្សាប្រវត្តគ្រួសារគាត់ទុក ដើម្បីផ្តល់ឱកាសដល់កូនចៅជំនាន់ក្រោយទៀតរបស់អ៊ុំ ពួកគាត់អាចមានឱកាសរៀន នឹងស្គាល់ពីជីវប្រវត្តរបស់អ៊ុំណាអ៊ុំ។

ខៈ ចាស។

កៈ ចាស អញ្ចឹងជាដំបូងខ្ញុំចង់សួរអ៊ុំថា តើអ៊ុំមានឈ្មោះពេញ ឈ្មោះក្នុងអតសញ្ញាណបទឈ្មោះអីគេដែរអ៊ុំ?

ខៈ ចាស ហែម សុថេន។

កៈ ហែម សុថេន?

ខៈ ចាស។

កៈ ចាស។ ហើយអ៊ុំមានឈ្មោះហៅក្រៅហ្អេស?

ខៈ អើ ឈ្មោះហៅក្រៅ ហៅអូន។

កៈ ហៅ អូន?

ខៈ ចាស។

កៈ ចាស ហើយអើ ហៅអូនហ្នឹង ហៅតាំងពីក្មេងមកឬក៏ចាស់ហើយ?

ខៈ ចាស អូនហ្នឹងហៅតាំងតែពីខ្ញុំនៅតូច។

កៈ ចាស។

ខៈ តាំងពីកើតមកម៉ែប៉ាខ្ញុំដាក់ឈ្មោះអញ្ចឹង។

កៈ ចាសអ៊ុំចាស។ ចុះអ៊ុំ អើ បើគិតមកដល់ឥឡូវអ៊ុំមានអាយុមាណហើយ?

ខៈ ចាស ខ្ញុំកើត ឆ្នាំដែរខ្ញុំកើតពិតប្រាកដគឺថ្ងៃទីប្រាំបួន។

កៈ ចាស។

ខៈ ខែដប់។

កៈ ចាស។

ខៈ មួយពាន់ប្រាំបួនរយហាបី។

កៈ ហ្អេរ អញ្ចឹងអ៊ុំអាយុ ប្រហែលជា?

ខៈ ហុកជាងហើយ។

កៈ ហុកជាង ចាសចាស។

ខៈ ចាស។

កៈ ចាស។ ហើយអើ តើឆ្នាំអ៊ុំ បើគិតជាឆ្នាំខ្មែរ ឆ្នាំអីគេអ៊ុំ?

ខៈ ចាស ខ្ញុំឆ្នាំម្សាញ់។

កៈ ឆ្នាំម្សាញ់ ឆ្នាំពស់អ៊ុំណា?

ខៈ ចាស។

ក៖ ចាសចាសអ៊ុំ។ ហើយអើ តើអ៊ុំដឹងថាអ៊ុំកើតនៅកន្លែងណាហ្អេស? ដូចជានៅភូមិអី? ស្រុកអី? ខេត្តអី?

ខ៖ ចាស ដឹង អើ ខ្ញុំកើតនៅភូមិទឹកល្អក់ សង្កាត់លេខបី ក្រុងភ្នំពេញ។

ក៖ ចាស អញ្ចឹងអ៊ុំនាក់នៅទីក្រុងភ្នំពេញតាំងពីក្មេង?

ខ៖ ចាស។

ក៖ ចាសចាសអ៊ុំ។ ហើយសំរាប់អ៊ុំ តើអ៊ុំមានបងប្អូនប៉ុន្មាននាក់ដែរ?

ខ៖ ចាស ខ្ញុំមានបងប្អូន១៨នាក់?

ក៖ ហ្អរ ១៨នាក់?

ខ៖ ចាស។

ក៖ ច្រើនណាស់អ៊ុំណា?

ខ៖ បងប្អូនបង្កើតម៉ង។

ក៖ ហ្អរ ច្រើនមែនទែន។

ខ៖ ហាហាហា។

ក៖ ហើយតាំង ទាំងដប់បួននាក់ហ្នឹង នៅមានជីវិតទាំងអស់ហ្អេសអ៊ុំ?

ខ៖ ចាស ស្លាប់នៅជំនាន់ពលពតខ្លះ។

ក៖ ចាស។

ខ៖ ហើយខ្លះទៀតស្លាប់នៅក្នុងជំនាន់ នេះ។

ក៖ ជំនាន់ឥឡូវ?

ខ៖ ចាស។

កៈ ចាស ហើយឥឡូវនៅសល់មាណាអ៊ុំ?

ខៈ (គាត់កំពុងគិត) នៅប្រាំមួយនាក់។

កៈ ហ្អារ នៅសល់ប្រាំមួយនាក់?

ខៈ ចាស។

កៈ ចាសអ៊ុំចាស។ ហើយអ៊ុំជាកូនទីមាណាដែរ?

ខៈ អើ ខ្ញុំជាកូនទីប្រាំ។

កៈ ហ្អារ អ៊ុំជាកូនទីប្រាំអ៊ុំណា?

ខៈ ចាស។

កៈ ហើយអើ តើអ៊ុំអាចរៀបរាប់ឈ្មោះបងប្អូនរបស់អ៊ុំ តាំងពីកូនទីមួយរហូតដល់កូនទីដប់បួន ហ្អេស?

ខៈ ចាស បាន។ អើ បងស្រីទីមួយឈ្មោះ ហែម ទេកពកន្និកា។

កៈ ចាស។

ខៈ ហៅ ហែម ថុន។

កៈ ចាសចាស។

ខៈ បងប្រុសទីពីឈ្មោះ មាគ ក៏ប៉ុន្តែមិនដឹងនៅក្នុងសំបុត្រកំណើតគាត់ដឹងជាឈ្មោះអីហ្អេស ក៏ប៉ុន្តែគាត់ស្លាប់តាំងពីតូចមកមេស។

កៈ ហ្អារ ចាស។

ខៈ ហើយ បងប្រុសទីបីឈ្មោះ ហែម សុថន។

កៈ ចាស។

ខៈ បងប្រុសទីបីឈ្មោះ ហែម សុថន។

ក៖ ចាស។

ខ៖ ហើយ បងប្រុសទីបួនឈ្មោះ ហៃម សុថេត។

ក៖ ចាស។

ខ៖ ហើយ ខ្ញុំទីប្រាំឈ្មោះ ហៃម សុថេន។

ក៖ ចាស។

ខ៖ ហើយ ប្អូនស្រីខ្ញុំឈ្មោះ ហៃម សុធី។

ក៖ ចាស។

ខ៖ ហើយមួយទៀតឈ្មោះ ហៃម សុខឿន។

ក៖ ចាស។

ខ៖ ហើយ ប្អូនប្រុសមួយទៀតឈ្មោះ ហៃម សុធូ។

ក៖ ចាស។

ខ៖ ហើយ ប្អូនស្រីមួយទៀតឈ្មោះ ហៃម មួយលី។

ក៖ ចាស។

ខ៖ ហើយ ប្អូនប្រុសមួយទៀតឈ្មោះ ហៃម សុផាន។

ក៖ ចាស។

ខ៖ ហើយ ប្អូនស្រីមួយទៀតឈ្មោះ ហៃម សុធារី។

ក៖ ចាស។

ខ៖ ប្អូនប្រុសមួយទៀតឈ្មោះ ហៃម សុផាន។

ក៖ ចាស។

ខ៖ ហើយបានប្អូនស្រីមួយទៀតឈ្មោះ ហែម សុធារី។

ក៖ ចាស។

ខ៖ ហើយបានប្អូន មើល(គាត់កំពុងគិត) ប្អូនប្រុសមួយទៀតឈ្មោះ ហែម ពិសិទ្ធ។

ក៖ ចាស។

ខ៖ ហើយបានប្អូនស្រីមួយទៀត ហែម គឹមសី។

ក៖ ចាស។

ខ៖ នឹងប្អូនពៅឈ្មោះ ហែម សុធារី។

ក៖ ហ្អរ។

ខ៖ ហ្នឹងប្អូនប្រុស។

ក៖ ចាស និយាយទៅអ៊ុំចាំទាំងអស់ម៉ង ហិហិហិ។

ខ៖ ចាស។

ក៖ អើយ ឡូយមែនទែនអ៊ុំ ចាស អញ្ចឹងសំរាប់អ៊ុំ តើអ៊ុំនៅចងចាំសាច់រឿងអីខ្លះ នៅពេលដែរអ៊ុំនៅក្មេងៗជាមួយហ្នឹងបងប្អូនអ៊ុំ? ដូចជា តើអ៊ុំចូលចិត្តលេងអីខ្លះជាមួយគ្នារ? មានអនុស្សាវរីយ៍អីខ្លះជាមួយគ្នារហោអ៊ុំ?

ខ៖ អើ កាលពីសង្គម ប៉ាខ្ញុំគាត់ធ្វើការនៅខាងសាធារណៈការ ផ្នែកខាងសួនច្បារអញ្ចឹងពេលដែរទំនេរពីការងាគាត់ធ្វើសួនច្បារនៅមុខផ្ទះ។

ក៖ ចាស។

ខ៖ ព្រោះដីឡូទ៍ខ្ញុំហ្នឹង ក្បាល២០ បណ្ដោយ៣០ អញ្ចឹងវាធំ។

ក៖ ចាស។

ខ៖ អញ្ចឹងប៉ាគាត់ធ្វើសួនច្បារអោយលេងនៅមុខផ្ទះហ្នឹង គាត់អត់ដែរអោយកូនដើរទៅលេងនៅណាឆ្ងាយទេ អញ្ចឹងបងប្អូនខ្ញុំនាំគ្នារលេងលោតអន្ទាក់ លេងបិតពួន។

ក៖ ចាសចាស។

ខ៖ លេងចោលឈូង លេងបាល់អីអញ្ចឹង។

ក៖ ចាសអ៊ុំចាស។

ខ៖ ចាស។

ក៖ អ៊ុំមានអនុស្សាវរីយ៍ល្អជាមួយគ្នារ។ ចាសអ៊ុំ ហើយអើ សំរាប់អ៊ុំ តើម្ដាយរបស់អ៊ុំឈ្មោះអីគេដែរ?

ខ៖ ចាស ម្ដាយខ្ញុំឈ្មោះ ហុង ប៉ូល។

ក៖ ហុង ប៉ូល?

ខ៖ ចាស។

ក៖ ចុះឪពុក?

ខ៖ ប៉ាខ្ញុំឈ្មោះ ហៃម ខុន។

ក៖ ហៃម ខុន?

ខ៖ ចាស។

ក៖ ចុះអើ ពួកគាត់ទាំងពី បើគិតមកដល់ឥឡូវគាត់មានអាយុមាណហើយអ៊ុំ?

ខ៖ ប៉ាខ្ញុំទំនងប្រហែលជាគាត់ប៉ែតជាងហើយ ព្រោះអីគាត់កើតឆ្នាំឆ្លូវ។

ក៖ ហ្អេរ អាយុច្រើនហើយ?

ខ៖ ចាស។

ក៖ ហើយចុះម្ដាយ?

ខ៖ ម្ដាយខ្ញុំឆ្នាំរោង ក៏ប៉ុន្តែកាលគាត់ស្លាប់ហ្នឹងខ្ទង់អាយុប៉ែតជាងហើយ។

ក៖ ហ្អរចាសចាស។ ហើយអញ្ចឹងអើ អ៊ុំចាំថាពួកគាត់កើតនៅឆ្នាំណាហ្អេស?

ខ៖ ចាស អត់ដឹងផង។

ក៖ អត់ចាំអ៊ុំណា?

ខ៖ ចាស។

ក៖ ចាសអ៊ុំ ហើយតើអ៊ុំដឹងថាពួកគាត់កើតនៅទីកន្លែងណាហ្អេស? ដូចជានៅភូមិអី អញ្ចឹងហា?

ខ៖ ម្ដាយខ្ញុំកើតនៅភូមិស្វាយ។

ក៖ ចាស។

ខ៖ ស្រុកព្រៃស្រឡិត។

ក៖ ចាស។

ខ៖ ហ្អរ! ភូមិព្រៃស្រឡិត។

ក៖ ចាស។

ខ៖ ស្រុកពារាំង ខេត្តព្រៃវែង។

ក៖ ហ្អរ ចុះប៉ា?

ខ៖ ប៉ាខ្ញុំកើតនៅភូមិគរ។

ក៖ ចាស។

ខ៖ ស្រុកហើយនឹងខេត្តដូចម្ដាយខ្ញុំដែរ។

ក៖ ហ្អរ ដូចគ្នារអ្នកនៅព្រៃវែង។

ខ៖ ចាស គ្រាន់តែភូមិផ្សេង។

កៈ ចាសចាស អញ្ចឹងអើ តើអ៊ុំដឹងថាឪពុករបស់អ៊ុំគាត់បានប្រកមមុខរបរអីគេខ្លះ ដើម្បីអើ រកប្រាក់កំរៃចញ្ចឹមជីវិតហ្អេស?

ខៈ ចាស ប៉ាខ្ញុំគាត់ធ្វើការនៅ ក្រសួងវឌ្ឍនៈ វប្បកម្ម នៅវឌ្ឍនៈ វប្បកម្ម។

កៈ ហ្អរ គាត់ធ្វើការរដ្ឋអ៊ុំណា?

ខៈ ចាស គាត់ធ្វើការរដ្ឋ តែគាត់ផ្នែកខាងសួនច្បារនាក់គ្រូវ។

កៈ ចាស។

ខៈ ព្រោះពីសង្គមខាងសួនច្បារនៅទីក្រុងភ្នំពេញលើប៉ាខ្ញុំនាក់គ្រប់គ្រងទាំងអស់។

កៈ ហ្អរ ចាសចាសអ៊ុំចាស។ ហើយអើ តើឪពុករបស់អ៊ុំគាត់ជាមនុស្សបែបណាដែរ? ដូចជាមនស្សកាចឬក៏ស្លូតអញ្ចឹងហា?

ខៈ ចាស ប៉ាខ្ញុំជាមនុស្សសុភាព ហើយគាត់ស្រឡាញ់កូនណាស់។

កៈ ហ្អរ ចាសចាស។

ខៈ រួចពួកខ្ញុំគឺរៀនសូត្រទាំងអស់ គឺអត់មានកូនណាមួយដែរថាអត់បានរៀនទេ។

កៈ ចាស។

ខៈ លើកលែងតែអាតូច វាកើតមកប៉ះចំសម័យសង្គ្រាម វាអត់បានរៀនទេ។

កៈ ហ្អរ ចាស។

ខៈ ចាស។

កៈ ចាសអ៊ុំចាស។ ចុះម្តាយរបស់អ៊ុំគាត់បានប្រកបមុខរបរអីគេដើម្បីអើ រកប្រាក់កំរៃចញ្ចឹមជីវិតគាត់ដែរ?

ខៈ ម្តាយខ្ញុំមេផ្ទះព្រោះគាត់គ្រប់គ្រងតែកូនគាត់១៩នាក់ហ្នឹង។

កៈ ហាត់?

ខ៖ ចាស។

ក៖ ចាស។

ខ៖ ព្រោះគាត់អត់មានពេលរកសីព្រោះគាត់នៅមើលថែកូន។

ក៖ ហ្អរ ចាស ចុះម្ដាយអ៊ុំគាត់ជាមនុស្សបែបណាដែរ?

ខ៖ ចាស ម្ដាយខ្ញុំគាត់ស្លូតក៏ប៉ុន្តែគាត់មឹងម៉ាត់។

ក៖ ហ្អរ ចាសចាស។

ខ៖ គាត់អត់ចេះអក្សរមែន ក៏ប៉ុន្តែមិនថាកូនរៀនពេលយប់ បើអត់កាន់សៀវភៅគឺគាត់ដើរគោះគ្រប់បន្ទប់កូនទាំងអស់ គាត់មើលថាតើកូនណារៀនឬអត់?

ក៖ ហ្អរ ចាសចាស។

ខ៖ ហើយសូម្បីតែយើងចង់មើលសៀវភៅរៀនហ្នឹង យកសៀវភៅរៀនអានពីសាលារមកហ្នឹងអាស្អីៗហ្នឹង យើងដាក់សៀវភៅរឿងនៅក្នុងអាសៀវភៅហ្នឹង មើលហ្នឹងក៏គាត់ដឹងថាយើងអត់រៀនដែរ។

ក៖ ចាស។

ខ៖ តែគាត់អត់ចេះអក្សរទេ។

ក៖ ចាសចាស តែគាត់ឆ្លាត។

ខ៖ ចាស។

ក៖ ឆ្លាតរបៀបដឹកនាំកូន។ចាសអ៊ុំ ហើយសំរាប់អ៊ុំ តើអ៊ុំនៅចងចាំសាច់រឿងអីខ្លះអំពីឪពុកម្ដាយអ៊ុំ? ដូចជាអ៊ុំមានអនុស្សាវរីយ៍អីខ្លះជាមួយពួកគាត់? ចូលចិត្តទៅណាជាមួយគាត់ដែរ?

ខ៖ ចាស ម៉ែប៉ាខ្ញុំគាត់ស្រឡាញ់កូនណាស់ ហើយប៉ាជូនកាល ពេលថ្ងៃអាទិត្យអញ្ចឹងគាត់ទៅជីកស្មៅនៅតាមជើងភ្នំបូគោ យកមកដាំនៅតាមសួនច្បារអញ្ចឹងហា។

ក៖ ចាស។

ខ៖ សួនច្បារនៅមុខវាំង តាមមាត់ទន្លេ តាមស្ទឹងៗអញ្ចឹង គាត់តែងតែយកអាឡានធំៗហ្នឹងទៅពី។

ក៖ ចាស។

ខ៖ ទៅហ្នឹងដាក់កូនយកទៅ ហើយនឹងកម្មករយកទៅជីកស្មៅ។

ក៖ ហ្អរ។

ខ៖ ពីជើងភ្នំបូគោហ្នឹងយកមកដាំ។

ក៖ ចាស ចាសអ៊ុំចាស។ អ៊ុំមានអនុស្សាវរីយ៍ល្អជាមួយគាត់ណាស់។

ខ៖ ចាស។

ក៖ ចាស ហើយអើ តើឪពុកម្តាយអ៊ុំ គាត់ធ្លាប់បានប្រាប់អ៊ុំអីខ្លះអំពីជីវិតរបស់ពួកគាត់ នៅពេលដែរពួកគាត់នៅក្មេងៗហ្អេស?

ខ៖ អើ ប៉ាគាត់អត់ គាត់បានប្រាប់ដែរក៏ប៉ុន្តែខ្ញុំស្គាល់តែតាខ្ញុំឈ្មោះតា ហែម។

ក៖ ចាស។

ខ៖ ហើយ យាយខ្ញុំឈ្មោះ យាយទេព។

ក៖ ចាសចាស។

ខ៖ ហ្នឹងម្តាយខាងឪពុក។

ក៖ ចាសអ៊ុំចាស។ ចុះអើ ឪពុកម្តាយខាង?

ខ៖ អើ ឪពុកម្តាយខាងម៉ែខ្ញុំ អើ ឈ្មោះតា ហុង ហើយនឹងយាយ ម៉ៅ។

ក៖ ហ្អរ អ៊ុំនៅចាំ។

ខ៖ តែម្តាយខ្ញុំជាកូនកំព្រាតាំងតែពីតូចៗនោះ បងប្អូនគាត់ហ្នឹងប៉ុន្មាននាក់ទេ គាត់ថាគាត់ហ្នឹងជាកូន បងប្អូនគាត់ហ្នឹងច្រើន។ ក៏ប៉ុន្តែពួកខ្ញុំស្គាល់ ដោយឡែកពួកខ្ញុំស្គាល់តែបីនាក់ទេ។

កៈ ហ្អរ ចាស។

ខៈ ព្រោះគាត់ស្លាប់អស់ទៅហា។

កៈ ចាសចាស។

ខៈ នៅសល់តែបងប្អូនស្រីរបស់គាត់បីនាក់។

កៈ ចាសអ៊ុំចាស ចាស។ ហើយ តើអើ អ៊ុំចាំថាជីដូនជីតារបស់អ៊ុំហ្នឹង ពួកគាត់កើតនៅថ្ងៃណា? ខែណា? ឆ្នាំណាហ្អេស?

ខៈ ចាស ខ្ញុំអត់ដឹងផង។

កៈ ចាសចាស។ ឬក៏អ៊ុំស្គាល់កន្លែងកំណើតរបស់ពួកគាត់ហ្អេស?

ខៈ ស្គាល់ បើខាងម្ដាយខ្ញុំហ្នឹង គាត់នៅភូមិស្វាយ ឃុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែង។

កៈ ចាស ចុះខាងឪពុក?

ខៈ ខាងឪពុក គាត់នៅភូមិគរ ឃុំដូចគ្នារហ្នឹង គ្រាន់តែថាខុសភូមិហ្អេស។

កៈ ចាសចាស ចុះអើ សំរាប់អ៊ុំ តើអ៊ុំធ្លាប់ដឹងរឿងអីខ្លះអំពីជីដូនជីតាអ៊ុំ? ដែរជីវិតរបស់ពួកគាត់បានឆ្លងកាត់មកហ្អេស?

ខៈ ចាស បើថាជីតាខ្ញុំ ពីដើមគាត់ជាគ្រូវខ្មែរ។

កៈ ហ្អរ ចាស។ ហើយចុះ អើយាយ?

ខៈ ហើយជីដូនខ្ញុំអត់ទេ គាត់នៅតែផ្ទះ ជីដូនខ្ញុំសុំតែសល់ហ្អេស។

កៈ ហ្អរ ចាស ចាស។ ហើយគាត់ប្រកបមុខរបរ ឬក៏គាត់ជាមនុស្សបែបណាដែរអ៊ុំ?

ខៈ យាយខ្ញុំស្លូត។

កៈ ចាស។

ខ៖ តាខ្ញុំក៏ស្លូតដែរ ក៏ប៉ុន្តែពួកខ្ញុំនៅជាមួយគាត់អត់បានយូទេ ព្រោះខ្ញុំទើបតែអាយុបានប្រាំពីប្រាំបីឆ្នាំតាខ្ញុំស្លាប់។

ក៖ ហ្អរ ចាសចាស ចាស។ ហើយសំរាប់អ៊ុំ តើអ៊ុំបានមករស់នៅទីក្រុងភ្នំពេញនេះអស់រយះពេលមាណឆ្នាំហើយ?

ខ៖ និយាយរួមទៅ តាំងពីខ្ញុំកើតមក ខ្ញុំដឹងនៅហ្នឹងម៉ង។

ក៖ បើគិតទៅវាអើ ស្មើរនឹងអាយុអ៊ុំ?

ខ៖ ចាស។

ក៖ ហ្អរ អញ្ចឹងអ៊ុំនៅយូមែនទែនម៉ង ហិហិ ចាស។ អ៊ុំតើអ៊ុំមានសាច់ញាតិណាផ្សេងទៀតដែររស់នៅក្រៅប្រទេសខុសពីស្រុកខ្មែរហ្អេស? ដូចជានៅប្រទេសផ្សេងហា?

ខ៖ ចាស អត់មានហ្អេស។

ក៖ អត់មានសោះម៉ងណាអ៊ុំណា?

ខ៖ ចាស។

ក៖ ចាស ចាសចាស។ ហើយអើ តើស្វាមីរបស់អ៊ុំ គាត់ឈ្មោះអីគេដែរ?

ខ៖ អើ កាលជំនាន់ពលពត គេជំលៀសទៅ គេអោយខ្ញុំរៀបការជាមួយនឹងអើ នាក់មូលដ្ឋានហ្នឹងឈ្មោះ សំ ប៊ុនធឿន។

ក៖ សំ ប៊ុនធឿន?

ខ៖ ចាស។

ក៖ ចាស ហើយចុះអើ អ៊ុំរៀបការនៅឆ្នាំណាដែរ?

ខ៖ អើ ឆ្នាំ១៩៧៧។

ក៖ ១៩៧៧?

ខ៖ ចាស។

ក៖ ចាស ហើយការរៀបការនេះត្រូវបានរៀបចំឡើងដោយឪពុកម្ដាយ ឬក៏អ៊ុំរៀបចំវាឡើងដោយខ្លួនឯង?

ខ៖ ចាស រៀបចំឡើងដោយអង្គការខាងពលពតហ្នឹងម៉ង។

ក៖ ហ្អរ ខាង។

ខ៖ ព្រោះរៀបការហ្នឹង ទាំងគូៗគេអោយចាប់ដៃគ្នារហ្នឹង កាលខ្ញុំការហ្នឹងគឺ៥០សិបគូ។

ក៖ ហ្អូយ ច្រើន។

ខ៖ ចាស។

ក៖ ហើយចាប់ដៃរគ្នារហើយ គ៏បានតមករហូតមក?

ខ៖ ចាស អត់ទេដល់ពេលជំនាន់គេមុនវៃបែកភ្នំពេញហ្នឹង គាត់ចូលមកខាងរតណៈសេសង្គ្រោះជាតិហ្នឹង។

ក៖ ចាស។

ខ៖ ហើយក៏បែកគ្នាររហូតម៉ងទៅ។

ក៖ ហ្អរ បែកគ្នាររហូត អ៊ុំណា?

ខ៖ ចាស។

ក៖ ចាស ចាស។ ហើយនៅពេលអ៊ុំរៀបការហ្នឹង អើនៅពេលអ៊ុំប្រុសចូលស្ដីដណ្ដឹងអ៊ុំ តើអ៊ុំមានទទួលបានថ្លៃជំនូនឬគេហៅថាថ្លៃទឹកដោះហ្អេស? សម័យឥឡូវហ្អា?

ខ៖ សម័យឥឡូវ ខ្ញុំអត់មាន ហឹមមានគ្រួសារក្រោយទៀតហ្នឹង គឺគេអោយខ្ញុំហ្នឹងជាទឹកប្រាក់ចំនួនមាណទេនៀក? ចំនួន២០០ដុល្លា គ្រាន់តែថារៀបចំសែនព្រេនធម្មតាហ្អេស នាក់គ្រូរ។

កៈ ចាសចាសចាស។ ហើយអើ តើអ៊ុំអាចប្រាប់ខ្ញុំបានហ្អេស? អំពីមូលហេតុអី ដែរអ៊ុំស្គាល់គ្នារជាមួយហ្នឹងស្វាមីអ៊ុំ? តើជួបគ្នារនៅកន្លែងណា? ពេលណា? ហេតុអីស្រឡាញ់គ្នារអញ្ជឹងទៅណា?

ខៈ អើ ប្តីខ្ញុំហ្នឹងក្រោយហ្អេស?

កៈ ចាស អ៊ុំ។

ខៈ ហឹម គឺជួបគ្នារនៅពេលដែរខ្ញុំ ឈប់ធ្វើការពីសង្កាត់ហើយខ្ញុំកាត់ខោរអាវលក់ ដ៏អញ្ជឹងគាត់នាក់រត់ម៉ូតូឌុប។

កៈ ចាស។

ខៈ គាត់ក៏ ខ្ញុំហៅគាត់អី ឌុបក្រណាត់ឌុបអី ទៅទិញក្រណាត់ទិញអីហ្នឹង។

កៈ ចាស។

ខៈ ដល់តែហើយហ្នឹង យើងក៏ គាត់ចូលស្តីដណ្តឹងខ្ញុំមក។

កៈ ចាស អ៊ុំ។

ខៈ ខ្ញុំបានរៀបការជាមួយគាត់ហ្នឹង ពីឆ្នាំ ប្រហែលជាឆ្នាំ២០០០។

កៈ ២០០០?

ខៈ ចាស។

កៈ ឆ្នាំ២០០០។ ហ្អារ ១៧ឆ្នាំហើយ?

ខៈ ចាស។

កៈ ចាសអ៊ុំ។ ហើយអើ សំរាប់អ៊ុំ តើអ៊ុំចេះសរសេរនឹងនិយាយនឹងអានភាសារខ្មែរបានល្អប៉ុនណាដែរ?

ខៈ ចាស បើនិយាយភាសារខ្មែរអី ខ្ញុំរៀនបានច្រើន ព្រោះកាលពីសង្គមខ្ញុំរៀនដល់ថ្នាក់ ពាក់ដាណាល់ដែរ។

កៈ ហ្អរ ខ្ញុំរៀនបានច្រើនម៉ងហ្នឹងហា។

ខៈ ចាស។

កៈ ចាសអ៊ុំ។ ចុះអ៊ុំចេះភាសារផ្សេងខុសពីភាសារខ្មែរហ្អេស?

ខៈ ហិហិ អត់ចេះផងនាក់គ្រូរអើយ គ្មានបានរៀនសូត្រថែមទៀតផង។

កៈ ហ្អរ។

ខៈ ចេះៗ ចេះអាន តែដូចថាយើងនិយាយយើង។

កៈ អត់កើត?

ខៈ អត់កើត។

កៈ ភាសារអីគេអ៊ុំ?

ខៈ អង់គ្លេស នឹងបារាំង។

កៈ ហ្អរ។

ខៈ ចាស។

កៈ ហ្អរ ឡូយចេះពីភាសារ បារាំង អង្គគ្លេស។

ខៈ ចាស ព្រោះពីសង្គម គេក្មេងៗរៀនពីមតីរហូតដល់ថ្នាក់ទីប្រាពីចូលកូលេះ អាហ្នឹងគេអោយរៀនភាសារបារាំង។

កៈ ចាសចាស អូ្វ ឡូយមែនទែនអ៊ុំ។

ខៈ ចាស។

កៈ ហើយ តើអ៊ុំរៀនបានត្រឹមថ្នាក់ទីមាណដែរ?

ខ៖ ចាស ខ្ញុំបើនិយាយទៅ ខ្ញុំរៀនឥឡូវហ្នឹងជាថ្នាក់ទីមាណទេ ក៏ប៉ុន្តែពីសង្គមថ្នាក់ពាក់ដាណាល់ហ្នឹងគឺថ្នាក់ទីបន្ទប់ហើយ។ យើងប្រលងមួយឆ្នាំទៀត អាហ្នឹងយើងប្រលងបាក់អើ យើងចប់បាក់ឌុមហើយ យើងប្រលងចូលមហាវិទ្យាល័យ។

ក៖ ហ្អរ ចាស ចាស។ និយាយទៅអ៊ុំចប់អើ បាក់ឌុមម៉ង? យើងអាចគិតប៉ុណ្ណឹងណាអ៊ុំណា?។

ខ៖ ចាស។

ក៖ ចាសចាស ហើយអើ អ៊ុំរៀននៅសាលារណាដែរ?

ខ៖ ខ្ញុំដំបូង ខ្ញុំរៀននៅវិសេ អតរទេវី។

ក៖ ហ្អរ ចាស។ ហើយបន្ទាប់មក?

ខ៖ បន្ទាប់មកខ្ញុំដូទៅរៀននៅវិសេស៊ីសុវត្ថិ។

ក៖ ហ្អរ ចាស អ៊ុំរៀនសុទ្ធតែសាលារល្បីៗ ហិហិហិ។

ខ៖ ហិហិ ចាស។

ក៖ សាលារទាំងពីហ្នឹង រាល់ថ្ងៃនៅតែមាន? នៅតែរៀន?

ខ៖ ចាស នៅតើនាក់គ្រូរ។

ក៖ ចាស សំរាប់អ៊ុំ តើអ៊ុំមានមិត្តភក្រ័ណាដែរស្និតស្នាលដែរអ៊ុំបានធំធាត់ឡើងមកជាមួយគ្នារហ្អេស?

ខ៖ ចាស មានក៏ប៉ុន្តែគេបែកៗអស់រលីងហើយនាក់គ្រូរ។

ក៖ ចាស។

ខ៖ ព្រោះដល់តែពេលជំនាន់ពលពតហ្នឹង គឺពួកខ្ញុំបែកចេញពីគ្នារអស់រលីងហើយ។

ក៖ អត់មានទំនាក់ទំនងជាមួយគ្នារទេ?

ខ៖ ចាស មិនដឹងជាគេស្លាប់ មិនជាគេរស់។

កៈ ហ្អរ ចាស ចុះអ៊ុំនៅចាំឈ្មោះរបស់ពួកគាត់ហ្អេស?

ខៈ បើខ្ញុំចាំឈ្មោះ ខ្ញុំចាំឈ្មោះ គួយ ឡាង ហ្នឹងនៅផ្ទះរបស់ខ្ញុំ។

កៈ ចាស តែមួយហ្នឹងទេអ៊ុំណា?

ខៈ ចាស។

កៈ ចាសអ៊ុំចាស។ តើអ៊ុំចងចាំសាច់រឿងអីខ្លះអើ ដែរអ៊ុំបានធ្វើជាមួយហ្នឹងមិត្តភក្រ័អ៊ុំនៅពេលដែរអ៊ុំនៅក្មេងៗហ្អេស? ដូចជាអនុស្សាវរីយ៍ដែរអ៊ុំធ្លាប់លេងជាមួយគ្នារហ្អា?

ខៈ ចាស លេងជាមួយគ្នារ លេងបិទពួន លេងលោតអន្ទាក់។

កៈ ហ្អរ ចាស។

ខៈ ចាស។

កៈ ចាសអ៊ុំចាស។ ហើយចុះសំរាប់អ៊ុំ តើអ៊ុំធ្លាប់ធ្វើស្រែ ធ្វើចំការទេ?

ខៈ អត់ធ្លាប់ទេនាក់គ្រូវ ក៏ប៉ុន្តែដល់ពេលជំនាន់ពលពតវាជំលៀសទៅ។

កៈ បានចេះធ្វើ?

ខៈ យើងចេះ ចាស។

កៈ ហ្អរ ចាសចាស។

ខៈ ពីមុនមិនស្គាល់ដើមស្រូវមិចផង ហិហិ។

កៈ ហ្នឹងហើយដោយសារអ៊ុំកើតនៅភ្នំពេញ។

ខៈ ចាស។

កៈ ចាស អ៊ុំចាស។ អញ្ចឹងអើ សំរាប់អ៊ុំ នៅក្នុងជីវិតអ៊ុំ តើអ៊ុំធ្លាប់បានឆ្លងកាត់ធ្វើការអើមកខ្លះដើម្បីរកប្រាក់កំរៃដើម្បីចញ្ចឹមជីវិតហ្អា?

ខ៖ ចាស ចេញពីជំនាន់ពលពតចូលមករដ្ឋកម្ពុជា ពីមុនខ្ញុំទូលត្រីឆ្អើលក់នៅច្បារអំពៅ ខ្ញុំអត់ចូលមកដល់ទីក្រុងភ្នំពេញហ្អេ?

ក៖ ចាស។

ខ៖ ដល់ឆ្នាំ១៩៨០សិប ខ្ញុំចូលមកនៅជិតអើ ពេទ្យកុមារមញ្ញឹម។

ក៖ ចាស។

ខ៖ ហើយក្នុងហ្នឹងខ្ញុំមានតួនាទីជាប្រធានក្រុម។

ក៖ ហ្អរ ចាស។

ខ៖ ដល់តែពេលគេរៀបចំសង្កាត់ខ្ញុំ ខាងខ្ញុំហ្នឹងពីផ្លូវកម្ពុជាក្រោមមក មកដល់អង់ទែនទូរទស្សន៍ហ្នឹង។

ក៖ ចាស។

ខ៖ គេ គេរៀបចំជាសង្កាត់អើ លេខប្រាំពីរវិញ។

ក៖ ហ្អរ ចាស។

ខ៖ អញ្ចឹងដល់តែពេលនេះអញ្ចឹងប្រធានសង្កាត់គាត់ថាអោយខ្ញុំ អោយចូលធ្វើការជាមួយ ដំបូងខ្ញុំធ្វើការជាអនុប្រធានសមាគមនារីសង្កាត់

ក៖ ចាស។

ខ៖ ក្រោយមកទៀត ដល់ឆ្នាំ១៩៨១។

ក៖ ចាស។

ខ៖ ខ្ញុំបានជាប្រធានមណ្ឌល នៅមណ្ឌលប្រាំពីត្រឹមផ្សារមាន់អាំង។

ក៖ ចាស។

ខ៖ ជិតវិសេតន្ទូរះទេវីហ្នឹង។

ក៖ ចាស។

ខ៖ ហើយ ពេលហ្នឹងបានរដ្ឋគេប្រគល់ផ្ទះមួយអោយខ្ញុំដើម្បីអោយខ្ញុំស្នាក់នៅ។

ក៖ ចាស។

ខ៖ ជាមួយនឹងបងប្អូនហើយនឹងម្ដាយរបស់ខ្ញុំ។

ក៖ ចាសចាស។

ខ៖ ហើយដល់ពេល គេរៀបចំខាងសង្កាត់ គេក៏អោយខ្ញុំឡើងមកធ្វើជាអនុប្រធានដំណាក់សេកខណ្ឌទួលគោក។

ក៖ ហ្អរ ចាសចាស។

ខ៖ តែដល់ពេលនេះអញ្ចឹងទៅវាមានបញ្ហាពិបាក ព្រោះអីខាងអង្គការមហាជន គេច្រើនតែចុះសួរសុខទុក រួចភ្នែកខ្ញុំទន់។

ក៖ ហ្អរ។

ខ៖ អោយតែឃើញថាមានបញ្ហាអីពិបាកអីអញ្ចឹង ជួនកាលអោយខ្ញុំទៅសួរសុខទុកយោធាពិការនៅឯម្ដុំគៀនស្វាយហា កាលហ្នឹង។

ក៖ ចាស។

ខ៖ ដល់តែពេលខ្ញុំឃើញគេពិការអញ្ចឹង ឃើញគេពិបាកអញ្ចឹង ខ្ញុំចេះតែយំ រួចហើយកាលហ្នឹងគ្រួសារពលករ (ក) ប្រាំ កាលហ្នឹងគេមានការចាប់ទាហានចាប់អីអញ្ចឹងហា។

ក៖ ចាស។

ខ៖ ដល់ពេលនេះខ្ញុំឃើញខ្ញុំចេះតែពិបាក ថ្ងៃណាក៏ថ្ងៃខ្ញុំឃើញតែគេរបួសគេពាក់លី គឺគេអោយអង្គការមហាជនហ្នឹងចុះសួរសុខទុកហើយ។

ក៖ ចាសចាស។

ខ៖ ដ៏អញ្ចឹងខ្ញុំឃើញ វាពិបាក ឃើញថាក្រុមគ្រួសារគេយំហ្នឹង ខ្ញុំយំតាមគេរហូត។

ក៖ ហ្អរ។

ខ៖ ដំអញ្ចឹងខ្ញុំឡើងស្គមដូចកុកអញ្ចឹង។

ក៖ ចាស អាណិតគេ។

ខ៖ ចាស ដំពេលនេះអញ្ចឹងទៅ ខ្ញុំទ្រាំអត់បាន ខ្ញុំក៏ឈប់ពីការងាហ្នឹងទៅ។

ក៖ ចាស។

ខ៖ តែតាមពិតទៅអត់មានណាគេបញ្ឈប់ខ្ញុំទេ គឺខ្ញុំឈប់ខ្លួនឯង។

ក៖ ចាស ចាសអ៊ុំចាស។ ជួនកាលយើងអាណិតគេ ហិហិ។

ខ៖ ចាស ព្រោះថាយើងអត់មានដឹង មានស្អីដើម្បីជួយដោះស្រាយអោយគេអញ្ចឹងទៅណា។

ក៖ ចាស អ៊ុំ ចាសត្រូវហើយអ៊ុំចាស អញ្ចឹងនិយាយទៅអ៊ុំមានបទពិសោធន៍ការងាច្រើនមែនទែន។

ហើយអើ តាំងពីក្មេងរហូតមកដល់ឥឡូវ តើអ៊ុំឃើញថាជីវិតរបស់អ៊ុំ មានការផ្លាស់ប្តូរអីខ្លះក្នុងជីវិតហ្អេស?

ខ៖ ចាស ឃើញនាក់គ្រូវ។

ក៖ ចាស។

ខ៖ ពីមុន ពីក្មេងយើងធ្លាប់រស់នៅក្នុងក្រុមគ្រួសារដែរស្រណុកសុខស្រួល។

ក៖ ចាស។

ខ៖ ដឹងតែពីរៀន។

ក៖ ចាស។

ខ៖ ហើយ អត់ចេះធ្វើអីហ្អេស ហិហិ។

ក៖ ចាស ដំពេលឥឡូវ?

ខ៖ ដល់មកជំនាន់ពលពត យើងចេះធ្វើស្រែ យើងស្គាល់ដើមស្រូវ យើងស្គាលស្ទី ស្គាល់ពីការលំបាកអត់ឃ្លានយ៉ាងមិចយើងស្គាល់ហើយជំនាន់ពលពត។

ក៖ ចាស។

ខ៖ ដល់មកកាលរដ្ឋកម្ពុជា យើងពិបាកក្នុងការចញ្ចឹមបងប្អូនហើយនឹងម្តាយ។

ក៖ ចាស។ ចុះដល់ជីវិតសព្វថ្ងៃអុំ?

ខ៖ ដល់ជីវិតសព្វថ្ងៃ ដល់ពេលយើងអត់ធ្វើការបានយើង យើងនឹកស្តាយថា ហេតុអីបានជាយើងពេលហ្នឹង យើងគិតខ្លីឈប់។

ក៖ ចាស អុំចាស។

ខ៖ ហើយជីវិតយើងដែរ ធ្លាប់តែស្រួលហា ។

ក៖ ចាស។

ខ៖ ហើយមកពិបាកដល់ពេលសព្វថ្ងៃហ្នឹងអញ្ចឹងហាណាកូន។

ក៖ ចាសចាស ប៉ុន្តែអុំឃើញថា វាធូស្រាលជាងមុន ឬក៏ពិបាកជាងមុន?

ខ៖ ផ្នែកជីវភាពវាពិបាក។

ក៖ ចាស។

ខ៖ ក៏ប៉ុន្តែយើងមានជិត្តរីករាយដែរ ព្រោះថាយើងធ្វើស្អីក៏ដោយគឺយើងរកដោយកំលាំងញើសឈាមរបស់យើង។

ក៖ ចាស។

ខ៖ បើពីមុនយើងគ្រាន់តែសីញេតិចមកចេញលុយមកហើយ។

ក៖ ចាស។

ខ៖ តែឥឡូវអត់ទេ គឺយើងត្រូវបញ្ចេញកំលាំងពលកម្មរបស់យើង យើងបានលុយហ្នឹងវាមកដោយសុទ្ធវិច្ច។

ក៖ ចាសអ៊ុំចាស យើងក៏សប្បាយចិត្ត។

ខ៖ ចាស។

ក៖ ដែរបានមកពីសម្ដិភាពយើង។

ខ៖ ចាស។

ក៖ ចាសអ៊ុំចាស ហើយអើ សំរាប់អ៊ុំ តើអ៊ុំចូលចិត្តញាំម្ហូមអីគេដែរ?

ខ៖ ចាស ធម្មតាៗស្អីក៏ញាំបានដែរ។

ក៖ សម្លរ? គ្រៀមគ្រោះ?ឬក៏មិចអញ្ចឹងហាអ៊ុំ?

ខ៖ ចាស ជូនកាលស្លរទៅ ជូនកាលសាច់ជ្រូកចៀនទៅ។

ក៖ ចំរុះ។

ខ៖ ចាស ហិហិហិ។

ក៖ ហើយ តើអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេខ្លះដែរនៅពេលនៅក្មេង?

ខ៖ ខ្ញុំចូលចិត្តលេងប៊ិទពួន លោតអន្ទាក់។

ក៖ ចាស ហើយអីគេទៀតអ៊ុំ? អស់ហើយណាអ៊ុំណា?

ខ៖ ចាស តែប៉ុណ្ណឹង។

ក៖ ចាសអ៊ុំចាសចាស។ ហើយ សំរាប់ចម្រៀង តើអ៊ុំមានចម្រៀងណាដែរអ៊ុំបានរៀនពីក្មេងមកដែរអ៊ុំនៅតែចងចាំហើយចូលចិត្ត? ឬក៏អ៊ុំចូលចិត្តសម្រៀងប្រភេទណាដេរ? ដូចជាសម័យឥឡូវឬក៏ពីដើម?

ខ៖ ចាស ចូលចិត្តចម្រៀងសម័យពីមុន។

កៈ ហ្អារ សំនៀងរបស់ណាគេដែរអ៊ុំ?

ខៈ ចាសអើ ខ្ញុំចូលចិត្តចម្រៀងហ្នឹង មានរបស់នាក់ស្រី រស់ សេរីសុទ្ធា។

កៈ ចាស។

ខៈ ប៉ែន រ៉ន។

កៈ ចាស។

ខៈ ហើយនឹង ហ៊ួយ មាស។

កៈ ហ្អារ ពួកគាត់ច្រៀងពិរោះ ខ្ញុំចូលចិត្តដែរ ហិហិហិ។

ខៈ ចាស។

កៈ ចាសចាស អញ្ចឹងអើ សំរាប់នៅក្នុងក្រុមគ្រួសារអ៊ុំ តើអ៊ុំមាននរណាគេដែរចេះលេងឧបករណ៍ភ្លេងហ្អេស?

ខៈ ចាស អត់ទេ។

កៈ អត់មានសោះម៉ងណាអ៊ុំណា?

ខៈ ចាស។

កៈ ចាសចាស ហើយអើ និយាយពីផ្ទះរបស់អ៊ុំវិញ តើអើ ផ្ទះពីមុនហ្អាវាមានលក្ខណះមិចដែរអ៊ុំ? ពេលអ៊ុំនៅក្មេងៗ ដូចជាផ្ទះថ្ម? ផ្ទះឈើ? ឬក៏ផ្ទះស្លឹក ឬអីអញ្ចឹងហ្អា?

ខៈ ផ្ទះដែរនៅ។

កៈ កាលពីមុន?

ខៈ ជុំគ្នារជាមួយហ្នឹងក្រុមគ្រួសារខ្ញុំ គឺឈើលើក្រោកថ្ម គឺប៉ាខ្ញុំធ្វើផ្ទះពីល្វែងសំរាប់ជួលអោយគេ។

កៈ ហ្អរ ចាសចាស ហើយចុះអើ ផ្ទះហ្នឹងគឺត្រូវបានសាងសង់ឡើងដោយណាគេដែរ? ឬក៏អ៊ុំបានជួយសាងសង់វាឡើងហ្អេស?

ខៈ ប៉ា កាលហ្នឹងខ្ញុំនៅតូចៗ។

កៈ ហ្អរ អញ្ចឹងប៉ារបស់អ៊ុំនាក់សាងសង់វាឡើង?

ខៈ ចាស។

កៈ ចាស អញ្ចឹងអ៊ុំ តើអ៊ុំដឹងថាផ្ទះរបស់អ៊ុំហ្នឹង ពេលសាងសង់ឡើងត្រូវការសំភារះអីខ្លះហ្អេស?

ខៈ កាលហ្នឹង ប៉ាអោយបងប្រុសខ្ញុំហ្នឹង ទំនេរពីរៀនមកហ្នឹង ចាក់ពុំឥត។ ពុំឥតនៅផ្ទះហ្នឹង។

កៈ ហ្អរ ។

ខៈ ពុំឥតហ្នឹង មិនមែនដូចឥតដុំៗយើងឥឡូវទេ។

កៈ ចាស។

ខៈ គាត់មានពុំគាត់ហ្នឹង យកស៊ីម៉ង់លាយជាមួយនឹងខ្សាច់។

កៈ ចាស។

ខៈ ដាក់ទឹកដាក់អីដូចបាយអរអញ្ចឹង។

កៈ ចាស។

ខៈ ចាក់ចូលទៅក្នុងពុំហ្នឹងទៅ។

កៈ ហ្អរ ចាសចាស ហើយមានសំភារះអីគេ? ដូចជាដែក?

ខៈ ចាស មានដែរ។

កៈ មានឈលើ។

ខៈ ដែកហ្នឹងគឺពុំដែកគេម៉ងហា នាក់គ្រូវ។

កៈ ចាសចាស។

ខៈ រួចឥតហ្នឹងប្រហែលជា ប្រហែលជាប្រវែងវាប្រហែលជាមួយតឹក។

កៈ ចាសចាស។អញ្ចឹងផ្ទះហ្នឹងអើ ប៉ារបស់អ៊ុំនាក់សាងសង់ខ្លួនឯងឬក៏ជួលជាង?

ខៈ អើ ជួលជាង ប៉ុន្តែគ្រាន់តែថាឥតអីហ្នឹង។

កៈ ធ្វើខ្លួនឯង?

ខៈ ធ្វើខ្លួនឯង។

កៈ ចាសអ៊ុំចាស ពួកគាត់ គាត់ចេះធ្វើមកពីណាដែរអ៊ុំ?

ខៈ ខ្ញុំមិនដឹងដែរនាក់គ្រូរ។

កៈ ហ្អេរ ចាសចាស ហើយសំរាប់អ៊ុំ តើអ៊ុំមានជំនាញណាដែរអ៊ុំចេះមកតតមកពីគ្រួសារអ៊ុំ ហ្អេស?

ខៈ បើថាពីតូចដូចអត់មានជំនាញអីត្រូវតែពីរៀន។

កៈ ហ្អេរ ចាស។

ខៈ ព្រោះម៉ែខ្ញុំនៅតែផ្ទះ ទៅធ្វើការតែប៉ាម្នាក់។

កៈ ចាសចាស អញ្ចឹងអ៊ុំជំនាញច្រើនជាងគេគឺការសិក្សារ?

ខៈ ចាស។

កៈ ហើយអើ តើអ៊ុំអាចប្រាប់ខ្ញុំបានហ្អេស អំពីមូលហេតុអី? ចង់និយាយថា តើពេលណាដែរអ៊ុំមានការកំបាកបំផុតនៅក្នុងជីវិតរបស់អ៊ុំហ្អា?

ខៈ ការលំបាកបំផុតហ្អា  គឺការបែកបាក់ក្រុមគ្រួសារកាលជំនាន់ពលពតម៉ងនាក់គ្រូរ។

កៈ ហ្អេរ ចាសអ៊ុំ។

ខ៖ ព្រោះអីប៉ាអើ បែកបាក់នៅជំនាន់លុនណុលហ្នឹងគឺខ្ញុំបែកអើ គឺខ្ញុំចូលចិត្តមកអើ ១៧មេសារ គឺខ្ញុំចូលមកនៅជំនាន់ពលពតហ្នឹង គឺខ្ញុំបែកអើ បងប្រុសខ្ញុំម្នាក់ហើយនឹងបងស្រីខ្ញុំម្នាក់។

ក៖ ចាស។

ខ៖ ដល់តែពេលទៅជំនាន់ពលពត ខ្ញុំបែកប៉ាខ្ញុំ ហើយប្អូនៗខ្ញុំរស់នៅក្នុង ប្អូនៗខ្ញុំពីរនាក់ទៀត គឺត្រូវស្លាប់។

ក៖ ហ្អេរ អញ្ចឹងអ៊ុំមានការឈឺចាប់នៅពេលអ៊ុំបែកបាក់ក្រុមគ្រួសារអ៊ុំណា?

ខ៖ ចាស។

ក៖ ប៉ុន្តែទោះបីជាលំបាក អ៊ុំបានឆ្លងកាត់វាមកដល់សព្វថ្ងៃ អញ្ចឹងអ៊ុំបានឆ្លងកាត់វាមកយ៉ាងដូចម្តេចដែរ? ដូចជាអ៊ុំបានខំប្រឹងប្រែងហ្អេស?

ខ៖ ចាស ឆ្លងកាត់មកដល់សព្វថ្ងៃ ដូចខ្ញុំជំរាបនាក់គ្រូរអញ្ចឹង។

ក៖ ចាស។

ខ៖ ថាពីមុនខ្ញុំធ្លាប់ធ្វើការងានៅក្នុងអើរដ្ឋ អើការងាររដ្ឋ ខ្ញុំចញ្ចឹមបងប្អូនខ្ញុំទាំងអស់ ហើយប្អូនស្រីខ្ញុំម្នាក់ធ្វើការនៅរោងចក្រ។

ក៖ ចាស។

ខ៖ ខ្ញុំធ្វើការតែពីនាក់បងប្អូនហ្អេស ចេញពីអាពតមកដំបូងព្រោះអត់ទាន់មានការងាធ្វើ ប្អូនខ្ញុំទូលត្រីឆ្អើរពីអើ អើ អើ អើ។

ក៖ ពីណាអ៊ុំ?

ខ៖ ពីព្រែកក្មេង។

ក៖ ហ្អេរ។

ខ៖ ពីព្រែកក្មងមកច្បារអំពៅ។

ក៖ ចាស។

ខ៖ ខ្ញុំទូលត្រីឆ្អើរពីច្បារអំពៅ ទៅលក់នៅតាខ្មៅ ហើយទូលអង្ករពីតាខ្មៅមកច្បារអំពៅវិញ គឺថាពេលហ្នឹងវេទនាហ្អា គឺលំបាកមែនទែន។

ក៖ ហ្អរ ចាស។

ខ៖ ព្រោះទើបតែចេញពីពលពត។

ក៖ ចាស។

ខ៖ តែដល់ឆ្នាំ១៩៨០

ក៖ ចាស។

ខ៖ ខ្ញុំបានមកនៅជិតពេទ្យកុមារមេឈ្លើម ហ្នឹងខ្ញុំបានធ្វើប្រធានក្រុមជីវភាពខ្ញុំវាបានធូបន្តិច ព្រោះអីកាលហ្នឹងគេបើកពោតសំឡី បើកអង្ករ បើកម្ស៉ៅទឹកដោះគោ បើកសាប៊ូស្អីៗហ្នឹង។

ក៖ ចាស។

ខ៖ ខ្ញុំអាចចញ្ចឹមបងប្អូនខ្ញុំបាន ហើយក្រោយមកទៀតហ្នឹង ខ្ញុំបានមកសង្កាត់លេខប្រាំពី បងប្រធានសង្កាត់ លោកចំរើនហ្នឹង គាត់ហៅខ្ញុំអោយចូលធ្វើការងានៅសង្កាត់ទៅជីវភាពខ្ញុំគ្រួសារខ្ញុំនៅជាមួយហ្នឹងពូខ្ញុំ រដ្ឋគេប្រគល់ផ្ទះមួយនៅផ្សារ ម្តុំផ្សារមាន់អាំងហ្នឹង អោយខ្ញុំនៅ។

ក៖ ចាស។

ខ៖ អញ្ចឹងខ្ញុំអាចចញ្ចឹមបងប្អូនខ្ញុំបានធូធាពេលហ្នឹង។

ក៖ ចាស អញ្ចឹងអ៊ុំបានឆ្លងកាត់វាបានយ៉ាងល្អណាអ៊ុំណា?

ខ៖ ចាស។

ក៖ ចាសអ៊ុំចាស ហើយអើ តើអ៊ុំអាចប្រាប់ខ្ញុំបានទេ តើពេលណាដែរអ៊ុំគិតថាជីវិតរបស់អ៊ុំមានការសប្បាយហ្អា? សប្បាយជាងគេហ្អា? ពីបទពិសោធន៍ដែរសប្បាយៗហ្អា?

ខ៖ សប្បាយៗគឺនៅពេលដែរក្រុមគ្រួសារខ្ញុំជួបជុំគ្នារ ប្អូនហើយនឹងម្ដាយប៉ុន្តែទីបំផុតម្ដាយខ្ញុំគាត់ស្លាប់ប៉ុន្មានឆ្នាំនេះទៅ ហើយដល់ពេលនេះអញ្ចឹងទៅប្អូនៗក៏វាបែកបាក់ មានគ្រួសារគ្រប់ៗគ្នារអញ្ចឹងទៅ។

ក៖ ចាស។

ខ៖ វានៅឆ្ងាយ ឆ្ងាយពីគ្នារដ៏ ដ៏អញ្ចឹងទៅវាពិបាកហ្អា បើពេលនៅជុំគ្នារដូចកាលយើងពីក្មេងមិនដឹងជាសប្បាយយ៉ាងមិចទេនាក់គ្រូរ។

ក៖ ចាស ត្រូវហើយចាស តែជីវិតយើងុមានការផ្លាស់ប្ដូរ។

ខ៖ ចាស។

ក៖ ចាស ហើយសំរាប់អ៊ុំ តើតាំងពីក្មេងរហូតមកដល់ឥឡូវហ្អា អ៊ុំធ្លាប់មានបំណងប្រាថ្នារ ឬក្ដីស្រមៃដែរអ៊ុំចង់បាននៅពេលអ៊ុំធំឡើងហ្អេស?

ខ៖ ការប៉ងប្រាថ្នារខ្ញុំធំបំផុតគឺខ្ញុំចង់ធ្វើជាពេទ្យ។

ក៖ ហ្អរ ចាស។

ខ៖ ហើយ ប៉ាខ្ញុំនោះគាត់បណ្ដុះបណ្ដាលកូនហ្នឹង ព្រោះគាត់ក៏ចង់អោយខ្ញុំក្លាយទៅជាវេជ្ជះបណ្ឌិតដែរ ក៏ប៉ុន្តែទីបំផុតអត់បានអីសោះ។

ក៖ ហ្អរ ចាស ដោយសារតែប្រទេសយើងមានបញ្ហារ?

ខ៖ ចាស។

ក៖ ចាស ចាស ហើយឥឡូវជាចុងក្រោយ តើបើសិនអ៊ុំមានឱកាសដើម្បីផ្ដាំផ្ញើរដល់កូនចៅជំនាន់ក្រោយៗរបស់អ៊ុំហ្អា តើអ៊ុំចង់និយាយអីខ្លះទៅកាន់ពួកគាត់? តើអ៊ុំចង់អោយពួកគាត់ក្លាយជាមនុស្សបែបណា? ចង់អោយគាត់មានភាពជោកជ័យអីខ្លះនៅក្នុងជីវិត? ហើយចង់អោយគាត់រៀនអីខ្លះពីជីវិតរបស់អ៊ុំ?

ខ៖ ខ្ញុំសុំនិយាយចំពោះរូបខ្ញុំផ្ទាល់ ខ្ញុំមានចំណាប់អារម្មណ៏ចង់អោយកូនខ្មែរទាំងអស់ គឺធ្វើយ៉ាងមិចគឺអោយមានចិត្តស្រឡាញ់ គោរពដល់ម្ដាយឪពុក។

កៈ ចាស។

ខៈ ឪពុកម្តាយរបស់ខ្លួន ដែរជាឧប្បការីជនដែរមានគុណដែរមានជនបំផុតក្នុងជីវិតយើងម្នាក់ៗ។

កៈ ចាសអ៊ុំចាស។

ខៈ ហើយខិតខំរៀនសូត្រ ធ្វើយ៉ាងណាអោយជីវិតយើងរស់នៅ បានថ្លៃថ្នូរ នឹងមានឧត្តមគតិថាយើងស្រឡាញ់នាក់មានគុណយើងខ្លាំងបំផុត។

កៈ ចាសអ៊ុំចាស អញ្ចឹងអ៊ុំអស់ហើយ?

ខៈ ចាស។

កៈ អញ្ចឹងអរគុណច្រើនអ៊ុំ ហើយខ្ញុំអស់សំនួរផងដែរ ហើយអ៊ុំការសំភាសន៍នេះខ្ញុំនឹងយកទៅដាក់នៅក្នុងវេបសាយ៍របស់សាលារ BYU ដែរនៅសហរដ្ឋអាមេរិកហ្អាអ៊ុំ។

ខៈ ចាស។

កៈ ហើយឈ្មោះរបស់វេបសាយ៍ហ្នឹងគឺឈ្មោះថា www.cambodaioralhistriec.byu.edu អញ្ចឹងសំរាប់អ៊ុំ តើអ៊ុំអនុញ្ញាតិអោយខ្ញុំ ដើម្បីយកការសំភាសន៍របស់អ៊ុំដាក់ចូលទៅក្នុងវេបសាយ៍របស់សលារហ្អេសអ៊ុំ? អ៊ុំយល់ព្រមទេ?

ខៈ ចាស ស្រេចលើនាក់គ្រូរ បើថាខ្ញុំនិយាយហ្នឹងវាមានបញ្ហារលើសលួសច្រើន នាក់គ្រូរមិនបាច់ក៏បាន។

កៈ អត់អីទេអ៊ុំ។

ខៈ ចាស។

កៈ ចាស អញ្ចឹងអ៊ុំអនុញ្ញាតិដើម្បីអោយខ្ញុំដាក់ចូលមែនហ្អេ?

ខៈ ចាស។

កៈ ចាស អញ្ចឹងខ្ញុំអរគុណច្រើនណាអ៊ុំ។

ខ៖ ចាស។

ក៖ ហើយខ្ញុំដឹងថាអ្វីដែរអ៊ុំបានចែកចាយ អើនឹងពិភាក្សារជាមួយខ្ញុំអំពីប្រវត្តិរបស់អ៊ុំវានឹងជួយដល់កូនចៅជំនាន់ក្រោយរបស់អ៊ុំ។ នៅពេលដែរពួកគាត់ចូលបើកមើលគាត់នឹងឃើញថាជីវិតរបស់អ៊ុំបានឆ្លងកាត់មកអើ អ្វីខ្លះ ហើយគាត់នឹងដឹងថា តើអ៊ុំចង់អោយគាត់ក្លាយជាមនុស្សបែបណា ហើយគាត់នឹងរៀនអីខ្លះពីអ៊ុំអញ្ចឹងហ្នឹងណា។

ខ៖ ចាស។

ក៖ ចាស ហើយអរគុណច្រើនអ៊ុំ។

*(ការសង្ខេបពីខ្ញុំនិមល អ្វីដែរខ្ញុំចូលចិត្តពីជីវិតគាត់ថាគាត់ស្រឡាញ់ក្រុមគ្រួសារគាត់មែនទែន សឹងតែគ្រប់ម៉ាត់ដែរគាត់និយាយតែបងប្អូនក្រុមគ្រួសារគាត់ទាំងអស់។)*